ឯកសារទិន្នន័យគម្រោង (PDS) ដែលបកប្រែនេះ គឺផ្អែកទៅតាមសំណៅភាសាអង់គ្លេស ក្នុងគេហទំព័រ ADB.org ចុះថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០១៨។

ADB ASIAN DEVELOPMENT BANK

# ប្រទេសកម្ពុជា៖ គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធនៃសង្វាក់តម្លៃកសិកម្ម

| | | |
|---|---|---|
| ឈ្មោះគម្រោង | គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធនៃសង្វាក់តម្លៃកសិកម្ម | |
| លេខគម្រោង | 50264-002 | |
| ប្រទេស | ប្រទេសកម្ពុជា | |
| ស្ថានភាពគម្រោង | បានទទួលការអនុម័ត | |
| ប្រភេទគម្រោង/គំរូនៃការផ្តល់ជំនួយ | ហិរញ្ញប្បទានឥតសំណង<br>ឥណទានសម្បទាន | |
| ប្រភពមូលនិធិ/ចំនួន | **ហិរញ្ញប្បទានឥតសំណង៖ គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធនៃសង្វាក់តម្លៃកសិកម្ម** | |
| | ការផ្តល់ឥណទាន ដោយប្រើប្រាស់ធនធានមូលធនសម្បទានធម្មតា/មូលនិធិអភិវឌ្ឍន៍អាស៊ី | ២,១៧ លានដុល្លារ |
| | **ឥណទានសម្បទាន៖ គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធនៃសង្វាក់តម្លៃកសិកម្ម** | |
| | ការផ្តល់ឥណទាន ដោយប្រើប្រាស់ធនធានមូលធនសម្បទានធម្មតា/មូលនិធិអភិវឌ្ឍន៍អាស៊ី | ៦៧,៨៣ លានដុល្លារ |

| | |
|---|---|
| របៀបវារៈជាយុទ្ធសាស្ត្រ | កំណើនសេដ្ឋកិច្ច ដែលធានាបាននូវនិរន្តរភាពបរិស្ថាន<br>កំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នា |
| កត្តាជម្រុញឱ្យមានការផ្លាស់ប្តូរ | សមធម៌ និងការបញ្ជ្រាបយេនឌ័រ<br>អភិបាលកិច្ច និងការអភិវឌ្ឍន៍សមត្ថភាព<br>ដំណោះស្រាយចំណេះដឹង |
| | ភាពជាដៃគូ<br>ការអភិវឌ្ឍន៍វិស័យឯកជន |
| វិស័យ/អនុវិស័យ | **កសិកម្ម ធនធានធម្មជាតិ និងការអភិវឌ្ឍជនបទ**/ គោលនយោបាយកសិកម្ម ការអភិវឌ្ឍស្ថាប័ន និងការអភិវឌ្ឍសមត្ថភាព - កសិឧស្សាហកម្ម - ការបង្កើតទីផ្សារ និងពាណិជ្ជកម្ម - ហេដ្ឋារចនាសម្ព័ន្ធទីផ្សារជនបទ<br>**ដឹកជញ្ជូន** - គមនាគមន៍/ដឹកជញ្ជូនផ្លូវគោក (មិនមែនទីក្រុង) |
| សមធម៌ និងការបញ្ជ្រាបយេនឌ័រ | ការបញ្ជ្រាបយេនឌ័រប្រកបដោយប្រសិទ្ធភាព |
| សេចក្តីពិពណ៌នា | |
| សនិទានភាពនៃគម្រោង និងទំនាក់ទំនងជាមួយយុទ្ធសាស្ត្ររបស់ប្រទេស/ថ្នាក់តំបន់ | កសិកម្មនៅបន្តជាវិស័យដ៏សំខាន់សម្រាប់សេដ្ឋកិច្ចរបស់កម្ពុជា។ វិស័យនេះតែឯង ដែលក្នុងនោះរាប់បញ្ចូលទាំងការកែច្នៃ ការដឹកជញ្ជូន និងការធ្វើពាណិជ្ជកម្មផលិតផលកសិកម្មរួមចំណែក ៣៣,៧% ក្នុងផលិតផលសរុបក្នុងស្រុក (ផ.ស.ស)។ ផ.ស.ស នៃវិស័យកសិកម្មកើនឡើង ៤,៥% ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ ២០០៨ ដល់ឆ្នាំ ២០១២ ដោយសារការពង្រីកផ្ទៃដីដាំដុះ និងការឡើងថ្លៃខ្ពស់នៃតម្លៃកសិផល។ ទោះជាយ៉ាងណាក៏ដោយកំណើននៃវិស័យនេះថមថយមកវិញពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៦ (០,៩% ក្នុងមួយឆ្នាំ) ដោយសារតែការបាត់បង់កត្តាជំរុញទាំងនេះ ព្រមទាំងដោយសារព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ។ ផលិតផលកសិកម្មគឺជាផលិតផលនាំចេញធំជាងគេរបស់កម្ពុជា បន្ទាប់ពីផលិតផលវាយនភ័ណ្ឌ និងសម្លៀកបំពាក់ស្មើនឹង ៥៣៣ លានដុល្លារ (៥,២% នៃការនាំចេញសរុប) ក្នុងឆ្នាំ ២០១៦។ ទោះជាយ៉ាងណាក៏ដោយ ភាគច្រើននៃផលិតផលកសិកម្មដែលនាំចេញ គឺជាវត្ថុធាតុដើម ហើយការបន្ថែមតម្លៃដល់ផលិតផលទាំងនេះ ធ្វើឡើងក្នុង |

| | |
|---|---|
| | ប្រទេសផ្សេងទៀត។ ដើម្បីច្បាមយកឱកាសសេដ្ឋកិច្ចដែលបាត់បង់ទាំងនេះ និងធ្វើបច្ចុប្បន្នភាពសេដ្ឋកិច្ច ជាការសំខាន់ណាស់ដែលគេត្រូវពង្រឹងសង្វាក់តម្លៃនៃផលិតផលកសិកម្ម។ |
| ផលជះរយៈពេលវែង | ការបន្ថែមតម្លៃក្នុងវិស័យកសិកម្មត្រូវបានបង្កើន |
| លទ្ធផលរយៈពេលមធ្យម | ការបន្ថែមតម្លៃចំពោះផលិតផលកសិកម្មមួយចំនួនក្នុងតំបន់គម្រោងត្រូវបានបង្កើន |
| ធាតុចេញ | បរិក្ខារសម្រាប់ប្រើប្រាស់ក្រោយពេលប្រមូលផល និងបរិក្ខារឡជីស្ទីកត្រូវបានពង្រឹង។<br>ផលិតកម្មកសិកម្ម និងហេដ្ឋរចនាសម្ព័ន្ធសេវាកម្មត្រូវបានកែលម្អ។<br>ការភ្ជាប់ទំនាក់ទំនងនៅតំបន់ជនបទត្រូវបានបង្កើន។<br>ភាពជាដៃគូធុរកិច្ចរបស់តួអង្គពាក់ព័ន្ធនៃសង្វាក់តម្លៃត្រូវបានបង្កើន។ |
| ទីតាំងភូមិសាស្ត្រ | កំពង់ចាម កំពង់ធំ ឧត្តរមានជ័យ ព្រះវិហារ សៀមរាប ត្បូងឃ្មុំ |

**ប្រភេទនៃការការពារផលប៉ះពាល់**

| | |
|---|---|
| បរិស្ថាន | B |
| ការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត | B |
| ជនជាតិដើមភាគតិច | B |

**សង្ខេបទិដ្ឋភាពបរិស្ថាន និងសង្គម**

ទិដ្ឋភាពបរិស្ថាន

ការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត

ជនជាតិដើមភាគតិច

## ការប្រាស្រ័យទាក់ទង ការចូលរួម និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

| | |
|---|---|
| ក្នុងកំឡុងពេលរៀបចំគម្រោង | |
| ក្នុងកំឡុងពេលអនុវត្តគម្រោង | |
| មន្ត្រី ADB ដែលទទួលខុសត្រូវ | Ueda, Takeshi |
| នាយកដ្ឋាន ADB ដែលទទួលខុសត្រូវ | នាយកដ្ឋានអាស៊ីអាគ្នេយ៍ |
| ផ្នែក ADB ដែលទទួលខុសត្រូវ | ផ្នែកបរិស្ថាន ធនធានធម្មជាតិ និងកសិកម្មនៃនាយកដ្ឋានអាស៊ីអាគ្នេយ៍ |
| ទីភ្នាក់ងារប្រតិបត្តិ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>អគារលេខ ៤០ មហាវិថីនរោត្តម<br>រាជធានីភ្នំពេញ ប្រទេសកម្ពុជា |

## កាលវិភាគ

| | |
|---|---|
| ការអនុម័តលើទស្សនទាន | ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៨ |
| បេសកកម្មស្វែងរកការពិត | ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៩ |
| កិច្ចប្រជុំពិនិត្យឡើងវិញរបស់អ្នកគ្រប់គ្រង (MRM) | ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៩ |
| ការអនុម័ត | |
| បេសកកម្មត្រួតពិនិត្យលើកចុងក្រោយ | - |
| បច្ចុប្បន្នភាព PDS លើកចុងក្រោយ | ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៨ |

ទិន្នន័យគម្រោង (PDS) រួមមានព័ត៌មានសង្ខេបអំពីគម្រោង ឬកម្មវិធី៖ អាស្រ័យដោយ PDS គឺជាការងារមួយដែលកំពុងបន្ត ដូច្នេះព័ត៌មានមួយចំនួនអាចមិនត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងបឋម ប៉ុន្តែព័ត៌មានទាំងនោះនឹងត្រូវយកមកបន្ថែមនៅពេលដែលមានព័ត៌មាន។ ព័ត៌មានអំពីសំណើគម្រោង គឺជាព័ត៌មានដែលអាចមានការប្រែប្រួល និងជាព័ត៌មានបណ្តោះអាសន្នតែប៉ុណ្ណោះ។

ធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់ព័ត៌មាននៅក្នុងទិន្នន័យគម្រោងនេះ (PDS) ដើម្បីជាធនធានសម្រាប់អ្នកប្រើប្រាស់តែប៉ុណ្ណោះ ដោយពុំមានការធានាក្នុងទម្រង់ណាមួយឡើយ។ បើទោះបីជាធនាគារអភិវឌ្ឍន៍អាស៊ី ព្យាយាមផ្តល់មាតិកាប្រកបដោយគុណភាពខ្ពស់ក៏ដោយ ប៉ុន្តែព័ត៌មានត្រូវបានផ្តល់ជូន "ក្នុងលក្ខណៈមួយ" ដែលពុំមានការធានាក្នុងទម្រង់ណាមួយទេ មិនចំពោះថាជាការធានាដែលមានការបញ្ជាក់ច្បាស់លាស់ ឬជាការធានាដែលបង្កប់អត្ថន័យឡើយ រាប់បញ្ចូលទាំងការធានាដែលពុំមានការកំណត់ចំពោះភាពសមស្របសម្រាប់ទីផ្សារ ភាពសមស្របសម្រាប់គោលបំណងជាក់លាក់ណាមួយ និងការមិនរំលោភបំពាន។ ជាពិសេស ធនាគារអភិវឌ្ឍន៍អាស៊ី មិនផ្តល់ការធានា ឬភាពជាតំណាងណាមួយទៅលើសុក្រឹតភាព ឬភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មាននេះឡើយ។